# អារម្ភកថា

ព្រះរាជបណ្ណាល័យកម្ពុជា មានប្រាថ្នានឹងសាបបណ្ដុះបណ្ដាលវិជ្ជាកាព្យឲ្យរុងរឿងឡើងវិញ ព្រោះវិជ្ជានេះ បានសាបរលាបមកជាយូរឆ្នាំហើយ ក្នុងសម័យនេះ ពុំសូវឃើញមានពួកអ្នកកាព្យកវី ទោះបីជាមានខ្លះក៏មិនសូវកើត មិនទាន់ចិត្តកវីពីបុរាណ ការនឹងបណ្ដុះវិជ្ជានេះ គិតឃើញថា ត្រូវជ្រើសរើសអំបាល កវីនិពន្ធ គឺពាក្យកាព្យរបស់អ្នកប្រាជ្ញបុរាណ ដែលលោកតែងទុកមកបោះពុម្ពផ្សាយឲ្យមើលជាតួយ៉ាង ព្រោះកាព្យបុរាណដែលមានវោហារល្អៗ សឹងសមគួរជាគំរូនៅមានច្រើនណាស់ៗ រឿងកាកីព្រះរាជនិពន្ធនេះ ក៏នៅក្នុងចំណោមដែលត្រូវរើសយកធ្វើជាគំរូ ១ដែរ ទើបដាក់ឲ្យក្រុមរង្គនិពន្ធពិនិត្យ ។ ទៅយល់ឃើញផងថា គួរបោះពុម្ពផ្សាយជាគំរូ ទាំងដើម្បីរក្សាព្រះរាជនិពន្ធនេះមិនឲ្យសាបសូន្យទៅផង ។ រឿងនេះដឹងបានថាជាព្រះរាជនិពន្ធព្រះករុណាព្រះបាទសម្ដេចព្រះហរិរក្ខរាមាឥស្សរាធិបតី ( ព្រះបរមកោដ្ឋ ) ដោយសេចក្ដីព្រះរាជប្រារព្ធ សឹងមាននៅខាងដើមនៃរឿងនេះស្រាប់ថា ទ្រង់និពន្ធទុកក្នុងកាលពុទ្ធសករាជ ២៣៥៨ ព្រះករុណាព្រះអង្គនេះប្រាកដព្រះកិត្តិនាម

ដំៈល្បាសនៅដល់សព្វថ្ងៃនេះថា ជាឯកអគ្គអក្ខរប្រាជ្ញទ្រង់ជំនឿជំនាញ ក្នុងមគធភាសា និង កាព្យឃ្លោង រកគូប្រៀបបានដោយក្រ ។ ការដែលព្រះរាជបណ្ណាល័យយករឿងនេះបោះពុម្ពផ្សាយជឿថា គង់ជាទីពេញព្រះហឫទ័យព្រះរាជវង្សានុវង្ស និងជាទីពេញចិត្តនៃជនានុជនទាំងឡាយជាប្រាកដ ទំនងជាប្រយោជន៍ដល់អ្នកចំណង់សិក្សាកាព្យឃ្លោងខ្លះផង បើមិនច្រើនក៏តិច ។

រឿងនេះបានមកអំពីព្រះអង្គម្ចាស់ក្សត្រី មាលិកា ទ្រង់ប្រទានឲ្យជាសម្បត្តិរបស់ព្រះរាជបណ្ណាល័យ ។ សូមមានអំណរព្រះគេជព្រះគុណព្រះអង្គម្ចាស់នោះផង ក្នុងវេលាដែលចម្លងនឹងបោះពុម្ពបានស្វែងរកច្បាប់ឯទៀតមកផ្ទៀងផ្ទៀបគ្នាមើល ឃើញច្បាប់របស់ព្រះអង្គម្ចាស់នោះ ត្រឹមត្រូវល្អជាងគេ ទើបសម្រេចឲ្យយកច្បាប់នោះ តែទោះបីដូច្នោះ ក៏នៅមានទុកពាក្យខ្លះដែរបន្តិចបន្តួច សឹងប្រហែលមកអំពីអ្នកចម្លងភ្លាត់ទៅ ក៏បានកែយកតាមច្បាប់ដទៃដែលឃើញថាល្អជាង ។ វិធីប្រើអក្សរបានប្រើត្រឹមត្រូវយកតាមបែបសម័យនេះ ។

ព្រះរាជបណ្ណាល័យកម្ពុជា

ថ្ងៃទី ១១ យ៉ាំងវីយេរ ឆ្នាំ ១៩៣៤

# ព្រះរាជារម្ភកថា

១ - អង្គអញត្រកូល ជាតិជាកំពូល កម្ពោជជាទី
នុជ(១)នាថបូរ្យជា បុត្រាជាតី ក្នុងពជសុទ្ធី
សុខុមខត្តិយា ។

បរោកបុរី បុកណវេណី ទៅស្ថិតនៅនា
ក្រុងទេពនគរ កុលកចិត្តា តែងតាមបទបា-
លីលោកសម្តែង ។

ក្នុងប្រាំរយជាតិ បងជាបទបាទ កិច្ចកាព្យបាយបែង
ទុកជាតំណ តែងគតវង្ស ឲ្យអស់តម្លែង
ជនជាតិជីងជាន ។

ដំណើរដំណាល ស្រីស្រស់ពុតពាល ចិត្តជួសាមាន្យ
ទុកឲ្យស្ត្រី ៗ លោកិយមិញមាន មិត្តប្រុងប្រុសប្រាណ
ប្រុសប្រែអនិច្ចា ។

១ ពាក្យ នុជ នេះ មកពីពាក្យដើមថា “អនុជ” តែក្នុងទីនេះលុបអចេញ ព្រោះលើសពាក្យ ។

៥- ពុទ្ធសាសនំ អតិក្កន្តិ អដ្ឋបញ្ញា-
សតិសត ទេវសហស្សា មហាសករាជ
ឯកសព្តត្រីសព្ត ។
បុល្លូសករាជគ្រាន់ គ្រប់បានមួយពាន់ មួយរយរះរាប់
សេសចិតសិបប្រាំ – ពីរឆ្នាំតាំងចាប់ ថែងចនផ្គូផ្គាប់
កាព្យកែវកាកី ។

នៅនាពេលា ប្រថមយាមា យាមពុធរាត្រី
ពារពុធមួយផណ្ដប់ កើតគាប់ខែពី– សាខសូករី
សព្តសកា ។

៨- ពាក្យពោលពុំពី- រោះរាប់នៃនី- ទានតាមបទបា-
លីលោកដើមអាទ៏ ត្បិតជាតិប្រាជ្ញា ចេះចនសាសនា
ពុំសូវគួរសម ។



## ដំណើររឿង

១- នេះបទកាកកា(១). គិតែងចងជា រៀងរាយដោយដំ-
ណើរនៃព្រះមហា- ករុណាបានបំ- ពេញពោធិស-
ត្តារភូមិបារមី ។

យោនយកជាតិជា សត្វសកុណា គ្រុឌរាជបុត្រី
ស្ថេរស្ថិតឋាស្ថាន ពិមានសិម្ពលី រៀងរមគិរី
សុមេរុបព្វតា ។

ឯអង្គាលនោះ មានក្សត្រមួយឈ្មោះ ព្រហ្មទត្តរាជា
សោយរាជសម្បត្តិ ជាក្សត្រនៅនា នគរពារា-
ណសីឧត្តម ។

មែនមានបន្ទាយ ក្រៅក្រាស់ទូលាយ ខ្ពង់ខ្ពស់រូវ(២)ក្ដ

---

១ ដែលត្រូវគួរតែថា "នេះបទកាកគា - គិតែងចងជា" ព្រោះមកពីពាក្យដើមបា "កាកគតិ" ប្រែថា បទដំណើរក្អែកលោត ។ តែអ្នកអានធ្លាប់ថា "កាកកា" រត់មាត់មកហើយ ទើបយើងទុកឱ្យនៅដូចដែល ។ ២ រូវ ពាក្យបុរាណ ប្រែថា ធ្វូច ឬ បីធ្វូច ។

សិលាដាសដិត  ប្រកិតជិតជុំ  គួគន្ធទឹកទុំ
ភក់ជ្រៅធំធារ ។

៩- រាំងខាំងរាំងខណ្ឌ  សីមាជាជាន់  ជាជួរជាសជា
ដាសដិតប្រសព្វ  មណ្ឌបដោយទ្វារ  រូបយក្សមហិមា
គន់គួរស្ញប់ស្ញែង ។

ប៉ែកប៉មជ្រុងជ្រោយ  បណ្តែតបណ្តោយ  បណ្តាក់ខ្វាត់ខ្វែង
បញ្ចូងបញ្ចូ  រចនាតាក់តែង  ខ្ពង់ខ្ពស់ចិញ្ចែង
ចិញ្ចាចជាជួរ ។

នាងព្រាលៗប្រាក់  ជាជាន់ជាថ្នាក់  ជាថ្នល់គន់គួរ
រាំងតឿៗទាប  រៀងរាបជួរមួរ  ខ្វែងខ្វាត់ផ្សប់ផ្សួរ
ផ្សារផ្សារៀងរាយ ។

មើលមានប្រាសាទ  ប្រាំស្អាងគ្រោងគ្គណ៍ ស្អាត  ប្រសើរឆើតឆាយ
កំពស់កំពូល  ត្រសូលត្រសាយ  ត្រៃសតពណ្ណកយ
ពព្រាតគួរស្ញែង ។

គាន់ឃ្វាយកាន់សម  មុខព្រហ្មសុខ្ខព្រហ្ម  ត្រីសូល៍ឯកឯង



គ្រុឌចក់នាគជុំ  គ្រប់មុំត្រឡែង–  កែងគខ្វាត់ខ្វែង
ផងក្ដារជហ្វា ។

១០- សីងមាសពិចិត្រ  មណីរ័តន៍ដាំជិត  មុខជាប់រចនា
ប្រក់ប្រាក់ប្រុះព្រាត  ស្អាងស្អាតថ្ងៃថ្លា  ដូចស្ថានសួគ៌ា
ទិព្វទេពនិម្មិត ។

ទីខែនសុខសេ–  យ្យាសន៍យល់មាសម័យ  រចនាពិចិត្រ
ដាំត្បូងយល់យង់  បញ្ចង់ជុំជិត  ផ្កាស់ផ្ទុះពិពិធ
ពិព័ណ៌ល្អះល្អ ។

តាំងបីជាន់ចំ  ឡាក់លាយលេចលំ–  អអស់ត្រួយត្រ–
បកបទុមខែង  ចិញ្ចែងមានមូ–  លីលើលាយល
ជរដាយផ្ទាយផ្ទាក់ ។

ជាន់លើស័ក្ដិសម  រូបទេពប្រណម្យ  ជាន់កណ្ដាលដាក់
រូបគ្រុឌចក់នាគ  លូនលាកព័ន្ធពាក់  ជាន់ក្រោមគ្រុងយក្ស
ទ្រង់ទ្រគ្រតា ។

ពិគាននៀងកយ  ស្ទេកច្ឆ័ត្រឆាយ  ប៉ាំនប៉ាក់សុវណ្ណា

រំលេចស្រស់ស្រួល　រំយោលផ្កាលា(១) .　កែវកែវថ្លៃថ្លា
ព្រោងព្រាយរង្សី ។

១៩. ក្រឡាគំនាល់　មាលមាសកែមកាល់　កែវកែវរស្មី
ក្រឡាស្រីង្គារ　សែមសាស្រស់ស្រី　ដាំដិតមណី-
រ័ត្នរឿងសុវណ្ណ ។

បញ្ជរគ្រហាត់ត្រៃ(២) ប្រាសាទមាសម័យ　រចនាសោភ័ណ
ដំណាក់ស្នំស្និទ្ធ　ប្រកិតជាជាន់　ជាជួរគ្រប់គ្រាន់
ស្អាងស្អាតសោភា ។

រោងរថរាជយាន　គជេន្ទ្រសោតមាន　រៀងរៀបនានា
ឃ្លាំងគ្រឿងអាវុធ　មណីរ័ត្នសុវណ្ណា　ប្រាក់ភោជន៍ពស្ត្រា
ឃ្លាំងសព្វសារពើ ។

សាលាដំនុំ　បញ្ចាសឹងសម　សុសសព្វអន្ទើ
មានច្បារឧទ្យាន　សឹងមានគ្រប់ឈើ　ផ្លែផ្កាហើយធ្វើ
ស្រះស្រង់គង្គា ។

១ ច្បាប់ខ្លះថា រំយោលមាលា ។ ២ ច្បាប់ខ្លះថា ហោត្រៃ ។



មានមុខមន្ត្រី　ព្រាហ្មណ៍ព្រឹទ្ធកវី　ពិភេកហោរា
ជាងចេះការគ្រប់　ភ្លេងសព្វភាសា　ចម្រៀងរាំជា
ល្អ ៗ ប្រពៃ ។

២០. ពលគោកពលទឹក　ហាវហានពន្ទឹក　សឹងមានថ្វីដៃ
ប្រកបកម្លាំង　ធ្លាប់ច្បាំងមានជ័យ　ច្រើនណាស់ក្រាស់ក្រៃ
អនេកសល់សែន ។

ហើយមានព្រះគ័-　លៀងឰបុទ្ធិ　នាមនាដកូវេន
គន្ធ៌ន(១)សិល្បសាស្ត្រ　ធ្នុះធ្នាស់ស្ទាត់ក្មួន　លេចលើសទាំងដែន
កូមិកតទាំងឡាយ ។

ចេះទាំងដេញពិណ　ស្មោះស្មើទេវិន្ទ　បន្ទឺស័ព្ទសាយ
ប្រគុំចម្រៀង　ប្រួចប្រៀងល្បិចល្បាយ　ជាអ្នកប្រាជ្ញប្រាយ
គិតកិច្ចកាព្យា ។

ស្ដេចសោយសម្បត្តិ　ឥស្សូររម្យរដ្ឋ　លើសលើលោកា
ស្ដេចមួយរយមួយ . នាំសួយមាលា　មាសប្រាក់គេនា
មូលមកវន្ទីយ ។

១ ម. ជាគន្ធព្វ សំ. ជាគន្ធវ៌ តែនេះប្រើតាមសម្លេងសៀម ។

រាស្ត្រប្រជា ព្រាហ្មណ៍ព្រឹទ្ធហោរា- មាត្យមុខមន្ត្រី
សឹងសាន្តសុខសម ឥតអំពល់អ្វី ដោយបុណ្យបារមី
ក្សត្រក្សាន្តជាប្បង ។

២៩- ស្ដេចមានមហេសី នាមកែវកាកី ល្អល្អះឥតហ្មង
ឥតមានស្រីណា សោភាផ្ទឹមផង សមសព្វគន្ធង
កខ្ទោង(១)អស់ស្រី ។

កាយកើតអស្ចារ្យ អំពីផ្កាកា- ណិការសោភី
កត្រាសោភ័ណ ដូចចន្ទ្របូណ៌មី សក់ដូចកមរ៉ៃ
រលើបខ្នាញ់ខ្នៅ ។

លលាដ៍ពិលាស ដូចពិលមាស ទុំទែងផ្អូនផ្អៅ
មើលមាត់ញញឹម ប៉ប្រិមឥតសៅ ខឹមខាត់កាន់នៅ
សំដីសមសួរ ។

ថ្ពាល់ចាំងសងខាង ដូចផ្លែមាក់ប្រាង បំព្រងផងផ្ទូរ
នាសាសមសល់ ដូចកលគំនូរ ជាងចេះគន់គូរ
សួនសមសោភា ។

១ ប្បង, ផ្ដើម, កំពូល, ត្រូវគ្នានឹងពាក្យថា ខ្ទោង ។



ធ្មេញខ្មៅរលើក រលង់ប៉ផ្លុក ដូចនីលរតនា
កាណិកបល្អលន់ គួរគន់ដូចនា ត្របកបទុមា
កាយវិកស្រស់ថ្មី ។

៣០- ចិញ្ចើមខ្នាញ់ខ្នៅ កោងកបកល់កៅ– ទ័ណ្ឌាទន់ស្រស់ស្រី
នេត្រនាងថ្លាជ្រះ ស្រឡះពន្លឺ ដូចកលរស្មី
កញ្ចក់ជ្រះថ្លា ។

កកបមូលកុំ ផ្គត់បីជាទសម ស្នាសោតសោភា
គាងគូសមទ្រង់ គន់ត្រង់ហត្ថា ដូចដៃញាក-
វ័ណវិសេសសម ។

អម្រាមទន់តូច ពងវៀវឆ្មារដូច បន្ទាត្រៀវកុំ
ក្រចកជ្រះប្រាង សស្រាងហាក់ស- ម្បូរកែវអ្នកខំ
ខាត់ខឹមយល់យង់ ។

ដោះក្សត្របើល ត្របះគួរមើល ដូចផ្កាសត្តប-
ទ្ធ័ដកបក្រពុំ មូលកុំផ្ទូរផង ពងពៅរៀវប-
ង្កើះកបពិសី ។

ដើរសោតសសួល ដូចបេកមាសមូល សមសព្វឥតបី
អ្នកណាមួយមាន ដូចប្រាណកាកី ល្អអស់ឥន្ទ្រិយ
ឥតឯមានពាស់ ។

៣៩– សមសួនទាំងគ្រប់ ស្រួចស្រីស្រស់សព្វ សម្បុរលឿងច្បាស់
ដូចមាសនព្វគុណ ល្អលន់ពេកណាស់ មើលមិនមានពាស់
ក្រក្នែកស្រួលស្រេច ។

គបកាយក្រអូប ពោះតាំងកងរូប ប្រហើរពុំដាច់
រកផ្កាគ្រឿងអប់ ឈ្មុយឈ្ងប់សព្វសាច់ ពិដោរបណ្តាច់
បណ្តូលអស់ស្រី ។

បើនរនៃអ្នក ណាទឹងមិត្តភក្តិ ចូលចងបេតី
រួមសេស្នេហ៍ស្និទ្ធ ក្លិនជិតឥន្ទ្រិយ ប្រាំពីររាត្រី
ទើបបាត់គន្ធា ។

ព្រះបាទព្រហ្មទត្ត ស្តេចរួមប្រតិព័ទ្ធ ទឹងព្រះជាយា
សព្វព្រះហឫទ័យ មូលមៃត្រីស្នេហា ដូចដួងនេត្រា
ព្រះអង្គជាម្តង ។



សេពសុខកិរម្យ រួមឯកឆន្ទុំ ទន្ទឹមស្នេហ៍ស្នង
សព្វទិនរាត្រី បេតីឥតហ្មង ស្តេចទុកជាច្បង
ឯកអគ្គមហេសី ។

៤០– មានស្រីព្រះស្នំ ស្រីង្គារព្រះក្រម ស្រៀបស្រស់ប្រិមប្រិយ
តង់គាល់មហាក្សត្រ ព្រហ្មទត្តចក្រី របាំមហោរី
ល្អ ៗ គ្រប់ប្រាណ ។

រីកាលនោះណា ឯស្តេចគ្រុឌា ស្ថេរស្ថិតនៅស្ថាន
ចមបុងសិម្ពលី ជាទីវិមាន ទិព្យទេពាថ្កើងថ្កាន
ល្អល្អះប្រពៃ ។

ប្រកបកម្លាំង កម្លោះក្លោះខ្លាំង ហៀរហោះឯង
នភាអាកាស អហាស៍ព្រៀវប្រែ ផ្លោះម្តងផាប់ព្រៃ
មួយយោជន៍គណនា ។

អាចឆ្លងសាគរ សត្តសីទន្ទរ ដោយតេជឫទ្ធី
គ្រុឌទ្រង់ទិព្វមន្ត លើសលន់បក្សា ឫមថ្ងៃងកាយា
បានដូចចិត្តប្រាន ។

គ្រុឌតែងទៅលេង បាស្កា[1]ជាល្បែង ស្រើបស្រួលសំពន្ធ
និត្យនឹងមហាក្សត្រ ព្រហ្មទត្តថ្កើងថ្កាន គ្រុឌនិងក្សត្រក្សាន្ត
ឈ្នះចាញ់ស្មើគ្នា ។

៤៩- ហើយវិលវិញគង់ ស្ថិតស្ថានអម្ពុង លុះសត្តទិវា
ផ្អូកចិត្តចង់លេង ស្កាល្បែងមហា- ក្សត្រក្សាន្តគ្រុឌា
ចេញចាកសិម្ពលី ។

ហិចហើរហៀរហោះ ផ្ទាកផ្ទុកផ្ទាំងផ្ទោះ កណ្ដាលនភី
ឆ្លងសីទន្តរ សាគរគិរី ដូចដល់ធានី
និគ្រោធសាខា ។

ទើបក្រុងគ្រុឌរាជ ឫទ្ធីអំណាច និម្មិតអាត្មា
ប្រែប្រាណពីគ្រុឌ បរិសុទ្ធជាតិជា បុរសរូបា
ឆោមឆាយប្រពៃ ។

---

១ តាមទម្លាប់ដែលប្រើជា "បាស្កា" (ម. សំ. បាស ក៏មាន បាសក ក៏មាន) ។ តាមដែលយើងនិយាយសព្វថ្ងៃ ជួនកាលចោលបាត់អក្សរ បា ខាងដើមនោះបង់ នៅត្រឹមតែ សកា ហើយក្លាយជាស្កា ដូចពាក្យថាលេងស្កា បើនិយាយឲ្យត្រូវពេញជា "បាសកា" ។



ស្រេចចរចេញចាក លីលាលះលាក អំពីដើមជ្រៃ
យាត្រាត្រាច់ត្រង់ តម្រង់ទៅឮ ប្រាសាទក្សត្រថ្លៃ
ព្រហ្មទត្តរាជា ។

បើស្រីណាស្រើប ស្រស់ស្រួលសំរើប ដោយក្តីតណ្ហា
ឃើញរូបរាងឆោម ប្រលោមស្នេហា ចង់ចួបជិតជាប់
មិត្រភក្តិរួមប្រាណ ។

៥០- លុះដើរទៅទាល់ ទៅទៀបទីគាល់ ចុងរោងរាជស្ថាន
មាណពចូលដល់ យង់យល់ក្សត្រក្សាន្ត លំអុតអង្គប្រាណ
ធ្វើខ្លាចក្សត្រា ។

ព្រះបាទជៀស្ដជ័យ ស្ដេចទតទៅនៃ មាណពនោះណា
មែនមានព្រះសូរ មធូរទៅថា ហៃមាណពបា
ចូរចៅមកអាយ ។

ទើបស្ដេចឲ្យយក កូនស្កាក្ដារមក ក្រសាលសប្បាយ
នឹងក្រុងវេនតេយ្យ[1] ក្សត្រថ្លៃកេកាយ កំសាន្តសប្បាយ
សាន្តសុខទ័យា ។

---

១ វេនតេយ្យ, សុបណ្ណ, គរុឡ, គរុឌ; ទាំង ៤ សព្ទនេះជាឈ្មោះគ្រុឌ ។

កាលនោះមហេសី　គឺកៃកាគី　ឯកអគ្គធីតា
លុះសាយណ្ហ　ជ្រៀតជ្រែសុរិយា　គយគន់ព្រះមហា-
ក្សត្រក្សាន្តស្វាមី ៗ

ត្បិតបាត់មិនបាន　ស្ដេចចរចូលឋាន　មណ្ឌលខែនទី
ក្រឡាបន្ទំ　បរមសួស្ដី　ទើបវរក្សត្រី
ដណ្ដឹងទៅថា ៗ

៥៩– ហៃអស់ស្នំផង　ព្រះបាទព្រះបង　តើស្ដេចទៅណា
ទើបអស់ព្រះស្នំ　ប្រណម្យវន្ទា　ថាម៉ែហ្ងជា
អម្ចាស់គង់ឮ ៗ

ចុងពេលទ្រង់ស្ដា　ក្រសាលទឹងមា-　ណពនោះល្អក្រៃ
កាយគបនរល័ក្ខណ៍　វរក្ត្រប៉ប្រៃ　ប៉ប្រិមយល់ថ្ងៃ
នីអ្នកស្មើបាន ៗ

ល្អឥតឯទាស់　អំពើបោះបា-　ស្កាសមទឹងប្រាណ
ទើបកៃកាគី　ក្សត្រីកល្យាណ　ស្ដាប់ស្នំទូលឋាន
ត្នូបកើតបេតី ៗ



ឮថាមាណព　ល្អល្អះលើសលុប　លើសលែងលោកិយ
នាងនាថនិម្មល　ចង់យល់ឥន្ទ្រិយ　ចរចេញទៅខ្ញី
ជួបផល់ទាក ៗ

ឈរឈប់ផ្អាល់ផ្អាប់　គយគន់សាយសព្វ　អស់អង្គគ្រុឆា
ចាប់ចិត្តស្រឡាញ់　ពេកពេញចិន្ដា　ចង់បានបក្សា
ជាមិត្រស្វាមី ៗ

៦០– សុបណ្ណបក្សា　លេងស្កានទឹងមហា　ក្សត្រក្សាន្តធិបតី
ជួនបៃរក្ត្រគ្រង់　យល់អង្គកាគី　ត្នូបកើតមេត្រី
ត្រេកត្រង់កាមគុណ ៗ

ចិត្តគិតថាអេះ　នាងនេះល្អម៉្លេះ　នេះហៅល្អលន់
គ្រាកាលឃើញម្ដង　នេះហេងហៅបុណ្យ　គ្មានស្រីណាប៉ុន
ល្អពន់ប្រមាណ ៗ

អេះនេះហៅល្អ　ល្អម្លេះហៅក្រ　ក្ររកទៀតគ្មាន
អញធ្លាប់ឃើញសព្វ　ទឹងកប់មិនបាន　ពុំដែលឃើញមាន
ឲ្យល្អដូច្នេះ ៗ

អំបាលស្រីសួគ៌　　គំនាប់គំនួរ　　ម៉េចមិនដល់ម្ល៉េះ
ល្អដោយពណ៌ប្រាណ　　គង់មានទីតិះ　　ទាស់ខ្វះនេះអេះ
រកផ្គន់ក្អែកគ្មាន ។

នាងនេះយល់ជា　　មហេសីក្សត្រា　　ទើបនាងទាហាន
មកឈរពុំខ្លាច　　អំណាចក្សត្រក្សាន្ត　　គ្រុឌមើលរឹងម៉ាន
ចិត្តជាប់ស្នេហា ។

៦៩— ឯអគ្គការី　　យល់គ្រុឌបក្សី　　មើលមកអាត្មា
ញញឹមមើលមៀង　　ចំហៀងនេត្រា　　ឲ្យអគ្គគ្រុឌា
គ្រេកគ្រង់ហឫទ័យ ។

គ្រុឌគន់កាលណា　　ប្រទះនេត្រា　　នាងសើចប៉ប្រែ
ប៉ប្រឹមធ្វើរ្ហី　　ប៉េតីរវៃ　　កន្ទុយភ្នែកវៃ
ញញឹមដាក់មុខ ។

គ្រុឌយល់ដូច្នោះ　　ព្រួចព្រឺពុងពោះ　　ចុកអុក
ជាប់ចិត្តស្នេហា　　លេងស្កាពុំសុខ　　គន់គិតប៉ផ្អុក
ចង់មូលសម្ពន្ធ ។



ក្រឡាប់កគ្រា　　ក្រឡៅមើលស្កា　　ក្រឡាស់គយគន់
ក្រឡេកឈ្ងងឈ្ងៀង　　ចំហៀងលឹបលន់　　ក្រឡេកមិនឆ្អន់
មិនឆ្អែតនេត្រា ។

នាងធ្វើជាញាក់　　រសាយសូកាក់　　អំពីអង្សា
គ្រុឌយល់សុដន់　　ណែនក្តន់ទ្រា　　ព្រួចចិត្តចិន្តា
ស្រៀវស្រើបប្រតិព័ទ្ធ ។

៧០— ស្ទើរស្ទុះទៅឱប　　ពារពក្រសោប　　ហោះចេញទៅថ្ងាត់
មកគិតខ្លាចកើត　　ចំណោរមិនបាត់　　ខះខាំតែកាត់
ចិត្តចាំលេងស្កា ។

រីឯព្រះបាទ　　ព្រហ្មទត្តនរនាថ　　ទ្រើសទ្រង់សក្តា
កាលកាកីប្រែ　　វៀចវេរចិន្តា　　ពិតពីក្សត្រា
ពុំជ្រាបព្រះទ័យ ។

លុះព្រះសុរិយេ　　សែងសាយណ្ហេ　　ហើយនាងវិលវៃ
ចរចូលទៅក្នុង　　ទើបគ្រុឌវេនគេយ្យ　　ចិត្តចាំអាល័យ
មិនមានហៅស្បើយ ។

៧៣- គិតនឹងលួចលាក់ យកអង្គអយ៌អគ្គ- មហេសីឲ្យហើយ
គិតស្រេចពុំផ្សេង បង្អង់យូរឡើយ លាក្សត្រត្រាណត្រើយ
ចរចេញទៅខ្មី ។

## បទពំនោល

១– បទពោលកាលក្រុងគ្រុឌ- រាជរួសចរលី- លាលុះព្រះជ្រៃសាខា ។
សូត្រសេពទិព្វមន្តវិទ្យា ប្រែប្រាណវិញជា គ្រុឌពជរ៍ងថ្វិកនួង ។
ស្ទុះហោះផ្ទោះហើរហិចផ្សង លាទ់ព្ទឹកកង រំពង់នៃបក្ខាខែង ។
កាំងបិទបាំងសូរ្យសែង សូរសឹងស្ងប់សែង អន្ធការមេឃមីរមណ្ឌល ។
៥- សន្ធាប់សន្ធឹកបុទ្ធីពល បណ្តាលព្យុះខ្យល់ គគុកគគឹកមហិមា ។
កក្រើករំពើកពសុធា ញាប់ញ័ររសោះសា ទួទាំងទសទិសវិបត្តិ ។
ព្រះបាទបរមព្រហ្មទត្ត យល់អស្ចារ្យក្តាត់ ស្តេចស្តែងលាលីឆាប់ខ្មី ។
ចេញគង់ផ្តោះមុខអន្ត្រី អស់ទាំងសេនីយ៍ ផ្អូកផ្អើលរដយទទៃ ។
កាលនោះឯក្រុងវេនតេយ្យ ហិចហោះឆាប់ក្រៃ ដួចដល់នៃព្រះកៅរគារ ។
១០- ចរចូលគង់ខាងជិត តតក្អឹករសោះសា សំណេះសំណាលក្រៃអែស ។
ថាហៃហមាសថ្លៃពិសេស ពិសីទ្រទេស ទ្រទន់ទន់ភ្ងន់កាយា ។



បងយល់ពីថ្ងៃបងមហា ស្រឡាញ់ស្ងួនភ្ជា ទំពារមកដល់នេះហើយ ។
ម្តេចមេមាសមិត្រករន្តើយ ផ្តុំលក់ព្រងើយ ធ្វើហាក់មិនដឹងមិនយល់ ។
បងមករកប្អូនទិម្មល ប្តូមួយមាសស្កល់ ប្តូមិត្រមាសមិនមេត្រី ។
១៥- ឯអង្គបងនេះណាស្រី គឺមាណពពី- ថ្ងៃមិញនោះឯងហោងណា ។
បងនឹងនាំនាងយាត្រា ទៅទែនអាសនា ទីទិព្វសម្បត្តិសួគ៌ស្ថាន ។
ទៅសេពជាសុខសម្រាន្ត ប្អូនអើយពិមាន ទូរទមណ្ឌលទូលាយ ។
សឹងរតនទ៍ពិចិត្រព្រោងព្រាយ ព្រោងព្រាតលេចលាយ ប្រឡំសុវណ្ណរចនា ។
បងនឹងនាំទៅពុំងា ហៀរហោះហេហាស៍ ទៅលេងមើលអស់ទួលទី ។
២០- មើលសត្តបរិភណ្ឌគិរី សីទន្ទរជលធី ទាំងព្រះសុមេរុបពិត ។
មើលទាំងទព្វមហាសមុទ្រ ធារធំច្រោកជ ប្រកបទូវខ្យាបក់ក្រោល ។
ភ្ញីផ្ទើកគ្រឡេករន្ទាល រន្ទះផ្លេញផាល ប្រវាក់វិពេចទ៍រង្សី ។
ហើយទៅហិមពាន្តគិរី អនោតស្រះស្រី ព្រៃព្រឹក្សពន្លឹកពេញពាស ។
បងនឹងនាំមេមិត្រមាស លេងលើកៃលាស សំរេចសម្រាន្តឥន្ទ្រិយ ។
២៥- មើលទេពអប្សរកិន្នរី កិន្នរប្រិមប្រិយ ប្រដាប់ទូវគ្រឿងអស់អង្គ ។
សឹងរតនទ៍ពិចិត្របញ្ចង់ ព្រោងព្រាយរលង់ រលើបរលេចសោភា ។

ប្រួចប្រៀនរៀនរាំព្រមគ្នា   ថ្វាយវរវន្ទា   ព្រះឥស្សូរាគវម្តង ។
ដេញដំប្រគំភ្លាត់ក្មេង   ពីរោះល្វើយល្វេង   លទ្ធង់លន្ទោចលន់ព្រៃ ។
សាន្តសុខនិរទុក្ខសព្វថ្ងៃ   គន់គួរអាល័យ   ទីទិព្វសម្បត្តិសួគ៌នាយ ។
៣០- កុំប្អូនមាសមិត្រមេស្ពាយ   សម្បត្តិមនុស្សអាយ   មាសអើយមានតិច
កន្ទង ។

ចូរមាសមកទៅទីឋាន   សោយសុខគ្រប់គ្រង   សម្បត្តិសម្បូណ៌សួគ៌ា ។
លោមស្រេចទើបស្តេចគ្រុឌា   ត្រកងអង្គា   ថេរថើបអង្អែលអស់អង្គ ។
ស្រៀវស្រើបព្រួចព្រើប្រតិយុង   គ្រុឌខំប្រឹងប្រុង   សង្កត់ហឫទ័យបក្សី ។
ឯអង្គនាងកែវកាកី   ស្តាប់សព្ទសំដី   គន់គិតអល់ឯកគំនិត ។
៣៥- នឹងស្តីឲ្យជាអៀនមាត់   ចិត្តចូលប្រតិព័ទ្ធ   កក្តីសំឡាញ់ក្សត្រា ។
ហើយនាងធ្វើកលមាយា   ជានាងនិទ្រា   លក់លង់មិនដឹងខ្លួនប្រាណ ។
គ្រុឌយល់នាងនាថកល្យាណ   ធ្វើមិនដឹងឋាន   មានៅនៃគ្រុឌសោមនស្ស ។
ស្រេចពស្ពុះហោះប៉ុរហ័ស   តែមួយដំពាស់-   ដៃដល់សមុទ្រសាគរ ។
ផ្តាស់ផ្លូវសត្តសីទន្តរ   រំលងសត្តប-   រិភណ្ឌដល់ដើមសិម្ពលី ។
៤០- នានាំនាងចរចូលខ្ទី   ក្នុងឋានមន្ទីរ   មណ្ឌលនៃទេនសយនា ។



## បទកាកគតិ

៧៤- បទកាកគតិ   ក្រុងគ្រុឌបក្សី   ប្រែប្រាណកាខ្ម
រូបរូបទេវបុត្រ   ពិសុទ្ធសោភា   ឧបអង្គកែវកា-
កីកិតនាកី ។

នៃបទិត្យក្រសោប   ផ្គួញផិតអង្គឧប   អង្អែលផ្ទៀយ
ថើបថៃកាយា   កន្ត្រាកាកី   ក្ដួបកើតមេត្រី
ពាគរសេតណ្ហា ។

នាងកាកីកំ-   លៀងលបលួចសំ-   ឡក់លកិរិយា
ករកាត់ទទះទាត់   ប្រានផាត់គ្រុឌា   ទើបមានវាចា
ផ្តាស់ធ្វើយទៅឋាន ។

ឋានព្រះអង្គ   ពុំគួរគ្រេកគ្រន់   រួមរសជិតដាន
នឹងអង្គអញខ្ញុំ   យល់ពុំសមប្រាណ   ត្បិតខ្ញុំនៅមានៈ
ស្វាមីមិត្រហើយ ។

គួរប្ដីព្រះអង្គ ព្រះទ័យពុំត្រង់ ទឹងម្ចាស់ខ្ញុំឡើយ
លបលួចយកខ្ញុំ មកផ្ដុំផ្ដឹមខ្ទើយ ឱព្រះអង្គអើយ
ពុំគិតក្សត្រា ។

បំណាច់ចាប់ចិត្ត ជាមិត្រស្នេហ៍ស្និទ្ធ សំឡាញ់ផងគ្នា
ព្រះអង្គធ្វើបាន ពុំមានមេត្តា ព្រះទ័យព្រះមហា-
ក្សត្រក្សាន្តដល់តិច ។

៨០— ចង់បើខ្ញុំដោយ យូរទៅឯក្រោយ ស្រាប់តែទឹងគេច
យកស្រីសួគ៌ា ឯណាល្អលេច ម៉ោះហើយទឹងភ្លេច
បោលខ្ញុំចង់សៀត ។

បើម៉ោះសមខ្ញុំ ទឹងមានទុក្ខធំ ទ្រូងត្រួតបង្អៀត
ថែមទាំងជំនៀល គេងៀលផ្ទួនទៀត ថាស្រីស្រើបធ្មៀត
មានថ្ពត្រុឃា ។

ហើយគេទឹងងៀល ដំណាលជំនៀល ដល់ព្រះរាជា
ថាស្ដេចស្នែងស្នូះ លោកលះលីលា ទៅលួចករិយា
គេមកសិម្ពលី ។



ក្រុងក្រុឱធ្វើយថា បងដឹងហើយណា ប្អូនជាមហេសី
ស្ដេចទុកជាច្បង កន្ទង់លែងស្រី ហើយព្រះចក្រី
ស្រឡាញ់អស់អញ ។

ទោះបីបើក្ស- ត្រាទ្រង់ជ្រោមថ្វាត់ ក្រោធក្រៃគ្នាន់ក្នាញ់
បងពុំខ្លាចឡើយ ប្អូនអើយព្រឹកមិញ បើដោយស្រឡាញ់
ប្អូនមាសប្រសើរ ។

៨៤— តែគិតកើតកោះ បើកុំប៉ុណ្ណោះ កន្ត្រាក់យកយើរ
ពីមុខអ្នកស្ដេច បងផ្ដាច់មិនស្មើរ ពារពាហោះហើរ
មករួមស្នេហ៍ស្នង ។

ប៉ុន្តែការកើត ខ្លាចមានទាំងពីរ ទាំងប្អូនទាំងបង
បានជាបងឈប់ លុះយប់ទើបផ្គង នាំប្អូនមកគ្រង
ទីថែនសេយ្យាសន៍ ។

ប្អូនអើយមាសថ្លៃង មាសថាខ្លាចក្រែង ពាក្យពោលទាំងផ្ដាស
គេងៀលដល់បង ថាបងនាំមាស ហើរហោះវេហាស
មកស្ថានសួគ៌ា ។

នាកាលអញបង់ យកប្អូនស្នេហ៍ស្នង នោះមាននរណា
យល់ជាបងយក មាសមកស្នេហា ប្អូនអើយកុំបា-
រម្ភរិះការប្រាណ ។

អំបាលស្រីសួគ៌ គំនាប់គំនួរ ស្រៀបស្រស់កល្យាណ
ម្ដេចបងពុំប៉ង ចិត្តបងចង់បាន បានជាបងគ្មាន
ស្រីស្រស់កញ្ញា ។

៩០– ឯអង្គកាកី ចិត្តចង់មេត្រី ពាគសេតណ្ហា
ធ្វើពោលពាក្យពើ ថាយើសួគ៌ា គ្មានស្រីមួយជា
ត្រូវចិត្តប្ដីអ្វី ។

អំបាលស្រីសួគ៌ គំនាប់គំនួរ ម្ដេចមិនមេត្រី
ចុះអ្វីខ្ញុំជា មនុស្សនៅផែនដី កាលណាឡើយឥ
សូរសព្ទទ័យា ។

សព្វតែព្រះឧស្ម ព្រះអង្គថាប្រោស លើសលែងនានា
ព្រះបន្ទូលផ្អែម ល្ហិមល្ហែមណាស់សា ព្រះអើយខ្ញុំមហា-
សង្ស័យកន្លង ។



ទើបគ្រុឌលោមថា មែនហើយស្ងួនភ្ងា អស់ស្រីសួគ៌ផង
ល្អល្អះមែនពិត ឯកឥតមានហ្មង ប៉ុន្តែអញបង
ពុំត្រូវហឫទ័យ ។

ប្អូនអើយកុំប- (១)រម្ភវៀមក្រែងក្រ- ឡាប់លែងដោះដៃ
មង់ពោលពាក្យពិត ពិនិត្យពេកក្រៃ កុំស្ងួនសង្ស័យ
សន្ទិះសង្កា ។

៩៥– ហើយគ្រុឌចូលជិត ចូលចង់នៃបនិត្យ នៃបទិនស្នេហា
ឯកែវកាកី ក្សត្រីសោភា សំងំអង្គា
អង្គុយជួញជិត ។

កែមាត់នាងថា ឱះឱអនិច្ចា ពុំអាស្រូវចិត្ត
ក្បិតយល់ឯកឯង កំហែងប្រតិព័ទ្ធ ធ្វើបំបាត់មាត់
ពុំឲ្យឆ្លើយបាន ។

គ្រុឌបីក្រសោប ក្រកង់អង្គឱប អង្អែលអសប្រាណ
មួលមេចថៃថើប សំរេចសម្រាន្ត ផ្គុំផ្គឹមផ្កាល់មាន
ចិត្តបងមេត្រី ។

---

១ ដែលត្រូវជា បា· តែក្នុងទីនេះត្រូវឲ្យសម្ព័ន្ធជួននឹងពាក្យខាងក្រោយ គឺ "ក្រ" ។

រួមរក្សរសរូប　ក្រអែបក្រអូប　ផ្សាយផ្សព្វឥន្ទ្រិយ
ស្រើបស្រួលមូលមិត្ត　ជួញជិតប្រតី-　ព័ទ្ធពេញបេតី
សុខសេពចំណាន់ ។

គ្រុឌក្មួចនាគា　អាហារគោក្ដា　ជាចំអែតអង្គ
នាងក្មួចមហាក្សត្រ　ព្រហ្មទត្តទ្រើសទ្រង់　គ្រុឌក្មួចបោះបង់
ហេមពាន្តទូរទី ។

១០០– នាងក្មួចអស់ល្បែង　ខព្យានតែងលេង　កំសាន្តឥន្ទ្រិយ
គ្រុឌក្មួចឆ្លៀតឆ្លាត់　រង្គាត់ស្រះស្រី　នាងក្មួចបុរី
ស្ងំស្ងិមទុក្ខជស្ថាន ។

គ្រុឌបានកាកី　ពិសេសលែងស្រី　ពិដោរអស់ប្រាណ
សេពសុខមនោរម្យ　ផ្ទឹមផ្ទុំសម្រាន្ត　សំរើបរស់ប្រាណ
ឥតឯមានហ្មង ។

១០២– សេពសុខស្កប់ស្កល់　ទៀងទៀបទៅដល់　ទឹងបានកន្ទង
ត្រឹមត្រូវយាមា　បក្សាសូរសង　រងាវរំពង
រំពៃសុរិយា ។



# បទព្រហ្មគីតិ

១– បទព្រហ្មគីតិកាល　គ្រុឌស្នេហ៍ស្នាលនឹងកែវកា-
កីកាយកបគន្ធា-　រសារ៉ះនេះស្មេះបង្អង់ ។
បាប់បង់ទំនង់ទី-　ចានទៅពីក្សត្រទ្រើសទ្រង់
ពជវង្គកាលកើតក-　ន្ទួលរឹកវរកោលាហល ។
ដោយឫទ្ធិពជគ្រុឌា　បណ្ដាលជាព្យុះព្យាមសល់
លុះស្ងាត់បាត់ព្យុះខ្យល់　ស្ដេចចូលដល់ទៃនមណី ។
ពុំឃើញវរជាយា　នៅក្រឡាបន្ទំទី
ទៀងទើបព្រះភូមី　ស្មុគព្រះទ័យព្រះរាជា ។

៤– ស្ដេចគន់ស្ដេចគិតឆ្ងល់　បទពុំយល់វរជាយា
ដណ្ដឹងស្នំស្នេហា　នាងទៅណាបាត់ពុំយល់ ។
អស់ស្រីសឹងស្ងាំងកាំង　ភ័យកិតតាំងរត់របល់
រត់រកនាងនិម្មល　សព្វមន្ទីរមណ្ឌលា ។
បាត់សោះបាត់សូន្យសល់　រកពុំយល់វរធីតា
មកទូលមហាក្សត្រា　ស្ដេចរងើកាំងរងើគិតភ័យ ។

ស្ងួតស្ងំជ្រប់ព្រះភក្ត្រ    អន់អួលអាក់ក្នុងព្រះទ័យ
ក្តួលក្តៅទុកក្រៃ    គិតអាល័យអាឡោះលន់ ។
ទ្រង់ព្រះកន្សែងសោក    សែនអាមោក្សស្តាយពេកពន់
ព្រះផ្អកព្រះប្អូនតន់(១)    ខ្ញួញខ្ញឹងខ្ញេញថា ។
១០- ឱមាសមិត្រកល្យាណ    បងរកគ្នានស្រីឯណា
ឲ្យដូចកែវកនិដ្ឋា    ក្លិនក្រអូបក្រៃអែបឯង ។
ឱស្តាយភក្ត្រសោភ័ណ    ហាក់ព្រះចន្ទ្រត្រចះចែង
ស្ងួនសមជាស្តេចស្តែង    ឯកក្សត្រីស្រីកល្យាណ ។
ស្តាយចេះថែងចរចា    ស្តាយប្រាជ្ញាចេះរិះធ្យាន
ដឹងអត់ដឹងឱនប្រាណ    ដឹងសមគួរសមគាប់ការ ។
ស្តាយសមជាមហេសី    ធំលើសស្រីស្រស់ស្រីង្គារ
ស្តាយចេះដឹងសព្វសា-    រពើការពុំមានខ្វៃធ្វល់ ។
បំរុងស្រីបំរើ    ចិត្តស្មោះស្មើគ្មានកិច្ចកល

---

១ តន់ មកពីពាក្យថា រតន តែអ្នកតែងកាព្យត្រូវការពាក្យតែ ១ ម៉ាត់ កាត់យកតែត្រឹម តន មកប្រើក៏មាន ជូនកាលយកសំឡេងអក្សរដើម ១ ម៉ាត់ គឺរ័តន៍ មកប្រើក៏មាន ជូនកាលនិយាយថា រ័តន៍ ក៏មាន ។



ដឹងទោសដឹងទុក្ខទល់    អស់ស្រីស្នំស្និទ្ធទាំងឡាយ ។
១៩. បងរកបងរិះគ្រប់    ពុំប្រសព្វប្រសើរកាយ
ឲ្យដូចប្អូនឆោមឆាយ    ស្រីសំលូតសំឡាញបង ។
ឥឡូវប្អូនប្រែប្រាស    ព្រាត់និរាសវៀរហើយហោង
វៀររកនារីស្នង    ពុំដូចមាសមិត្រភ្ញាប្រិយ ។
ឱប្អូនធ្លាប់ផ្ដុំផ្ដឹម    ទៀបទន្ទឹមលើខែនទី
ពុំដែលពុំដាច់ពី    អង្គអញបង់បាត់ចេះណា ។
ឱប្អូនធ្លាប់គង់ជិត    នៅនៃបទិត្យនឹងវៀមក៏
ក្រសាលសុខទ័យា    ម្ដេចឡើយប្រាសនិរាសទៅ ។
ឱបងធ្លាប់យល់ភក្ត្រ    ប្អូនវរល័ក្ខណ៍គង់គាល់ហៅ
បំរើសព្វថ្ងៃនៅ    ឥឡូវបាត់បង់បងឆ្ងាយ ។
២០- ប្អូនធ្លាប់ស្រង់គង្គា    ទឹងវៀមក៏ក្សាន្តសប្បាយ
និរទុក្ខសុខស្កល់កាយ    រួមករម្យរសទាំងទ្វី ។
ឱប្អូនថ្ងៃត្រកាល    កំពុងពាលពេញពិសី
ពុំគួរឡើយប្អូនស្រី    ប្រាសចាកពីប្រសើរសុខ ។

ឱប្អូនទៅស្ថានណា  ជាសុខាឬទុក្ខ
ឬកាលកើតកលិយុគ  ក្រែងក្រុងគ្រុឌយក្សនាគផង ៗ
មកយកទៅពិសី  ទៅបេតីស្នាលស្នេហ៍ស្នង
ឱប្អូនអើយបើបង  ដឹងជាស្ថិតនៅស្ថានណា ៗ
បងនឹងតាមដោយដាន  គ្រាតែបានយល់កញ្ញា
ឥឡូវកែវកនិដ្ឋា  ឥតដំណឹងដំណួចឡើយ ៗ
២៥- ឱមាសមិត្រព្រលឹង  អស់ទន្ទឹងប្អូនម៉្លេះហើយ
ទុក្ខបងពុំគ្រាស្បើយ  គ្មានល្ហែល្ហើយពប់ពល់ថ្ងៃ ៗ
ស្ដេចសោកអគ្គជាយា  អន់អួលអាណិតណាស់នៃ
ជាទុក្ខរែងទុក្ខក្រៃ  ក្រៃលែងលើសទុក្ខនានា ៗ
វេលាផ្ទាប់ផ្ទុំលក់  ផ្ទុំពុំសុខសែនសោកា
ក្អួចទាំងស្រែងគង្គា  តាំងតែខ្ញួញតែទុក្ខនៅ ៗ
ពេលសោយក្រយាស្ងោយ  ស្ដេចសេពសោយតែសោកសៅ
ព្រះអង្គព្រះអួលក្ដៅ  ក្នុងព្រះទ័យតែងទុក្ខទល់ ៗ
ក្អួចក្អាំងទាំងក្រសាល  អស់អំពាលស្នំនិម្មល



ទាំងល្បែងលេងសុខសល់  តាំងតែខ្ញួញតែទុក្ខា ៗ
៣០- ទើបត្រាស់ឱ្យគេហៅ  គន្ធនទៅជួបចិន្ដា
ហើយប្រាប់ពីជាយា  បាត់អំពីប្រាសាទស្ថាន ៗ
គន្ធនដឹងហេតុហើយ  ទើបទូលឆ្លើយថាសូមទាន
កាលព្រះមហាក្សត្រក្សាន្ត  ទ្រង់ស្កាទឹងមាណពនោះ ៗ
ទូលព្រះបង្គំយល់  អ្នកនិម្មលទៅទារឆ្ពោះ
មើលមកមាណពនោះ  ឯមាណពឆ្មៀងនេត្រា ៗ
ញញឹមមើលទៅត្រង់  ទូលព្រះបង្គំក្រោធា
ទាន់ទ្រង់ព្រះករុណា  ពិសេសស្មើរស៊ីសាច់បាន ៗ
តែខំអត់កំហឹង  គិតជញ្ជឹងយល់សូមទាន
បើសិនជាប្រុសប្រាណ  នៅនានគរយើងអាយ ៗ
៣៥- ម្ដេចមិនថ្វាយបង្គំ  បើអ្នកអម្ចង់ស្ថានឆ្ងាយ
ខ្លាំងដើរម្ដេចអម្បាយ  ឆាប់ដល់ទៅដល់មកខ្ញី ៗ
យល់ថ្ងៃកទឹងមាណព  នៅពិតពត់ភូមិផែនដី
ខ្លាចក្រែងក្រុងគ្រុឌ  រាងរែងឫទ្ធិក្លែងប្លមអង្គ ៗ

មកលេងហើយលួចលាក់ ព្រះអង្គអគ្គទេពីពង្ស
ទៅសេពជាសាច់ស- ង្សារសំឡាញ់នៅសម្ពលី ។
ទូលព្រះបង្គំនេះ យល់ដូច្នេះដោយសេចក្ដី
សូមទានល្អងធូលី ព្រះបាទចាំប្រាំពីរថ្ងៃ ។
យល់ជាមកពុំទាន់ យើងនឹងបានគន់ពៃ
ឲ្យជាក់បើពិតនៃ តាមដោយដិតគង់ដឹងច្បាស់ ។
ហើយធ្វើកលឲ្យបាន ជូនកល្យាណមករម្យរដ្ឋ
គន្ធទូលមហាក្សត្រ ព្រះអង្គស្ដាប់គ្រាន់បានស្បើយ ។
ទើបស្ដេចត្រាស់ទៅផង ជាហៃហឫងគន្ធនអើយ
បើមែនដូច្នោះហើយ ឲ្យឯងអើយអញអរក្រៃ ។
ព្នោះបងទៅឲ្យឆាប់ នឹងក្រឡាប់វិលវិញវៃ
ចូរគន់គិតការភ័យ វៃវវៀសរក្សាកាយ ។
ត្បិតទៅក្នុងការក្រ ទឹកម្រមផ្លូវឆ្ងាយ
គន្ធនសោកក្រាបថ្វាយ វរវន្ទាព្រះបមបៅ ។
ឯក្សត្របរបូលក្ដាន ក្នុងពេលសានតែងសោកសៅ



ជាទុក្ខក្ដាត់ក្ដួលក្ដៅ នឹងនៃគាក៏កល្យាណ ។
ដំណាលដំណើរនេះ យើងទុកស្ទេះឈប់និទាន
នឹងថាថ្លែងដោយដាន ក្រុងគ្រុឌគ្រងនៃគាគី ។
ស្នេហ៍ស្នងស្នេហ៍ស្នាលស្និទ្ធ ចូលចាប់ចិត្តចងបេតី
បំណង់សេរមេត្រី សឹងសោមនស្សតាំងទូហារ ។

## បទភុជង្គលីលា

បទទ្រង់ភុជង្គលីលា ដំណើរពណ៌នា គ្រុឌទិងកាគី ។
សេពសមបន្ទំលើទី លុះព្រះសុរិយ(១) បាត់បង់ជ្រុងភ្នំ ។
បក្សីតើនពីបន្ទំ លោមនាងឧត្ដម គ្រេកត្រាស់ទៅថា ។
ប្អូនមាសរក្សសាភា បងនឹងយាត្រា នានាំប្អូនពៅ ។
លេងដោយជ្រុងជ្រោយព្រៃជ្រៅ មើលភ្នំហើយទៅ ស្រះស្រង់ផល-
ស័យ ។
ត្រាស់ស្រេចទើបស្ដេចវេនគេយ្យ បីបមស្រីថ្លៃ ចរចេញចាកទី ។
ហើយហោះចំពោះគិរី សុមេរុជាទី កំសាន្តទំយា ។

---

១ អ. ចិ. ស៊ី ។

រៀបរាប់ប្រាយប្រាប់ទៅថា ប្អូនអើយបពិត្រា សុមេរុវង្កុល ៗ
នាងអើយនេះហើយកំពូល ខ្ពង់ខ្ពស់បណ្តូល បណ្តាច់គួរស្ញែង ៗ
ត្រសែតអណ្តែតឯកឯង ត្រដួចចំពែង ចិញ្ចាចសឹងមណី ៗ
បពិត្រាថ្លៃថ្លាវង្ស ដូចសែងសុរិយ សន្ធោសន្ធៅ ៗ
ថ្មទទឹមថ្មាប្រាលផ្អៅ ប្រាលផ្អនទាប់នៅ ទាប់ទឹងថ្មទីល ៗ
មរកតពិសុទ្ធស្រស់ស្រិល ពព្រោងពព្រិល ប្រពាឡរ័តន៍កាយ ៗ
ថ្មពេជ្រផ្ទះលេចពីទាយ ពៃទូរ្យពណ្ណរាយ ពព្រោកបូបុស្ស ៗ
សត្តរ័តន៍នព្វរ័តន៍ស្រិលស្រស់ ភ្លឺផ្លេកទាំងអស់ ទាំងឯមុក្តា ៗ
ស្វាយប្រាលពពាលសថ្វា លឿងអនរគនា បៃតងខៀវខ្មៅ ៗ
ព្រាតប្រុះផ្ទាស់ផ្ទុះផ្អនផ្អៅ ផ្អនផ្អិតសន្ធៅ សន្ធោសន្ធឹ ៗ
ទតស្រេចទើបស្តេចបក្សី ហិចហើរហោះខ្វី ដល់សត្តបរិភណ្ឌ ៗ
ប្រាប់ឲ្យមើលដោយភ្នំខ័ណ្ឌ ទាំងប្រាំពីរជាន់ សុមេរុពជ ៗ
ប្អូនភ្ញាមើលរ៉ត្រដាច ត្រដឹងគួរខ្លាច ស្កឹមស្កៃបវរ ៗ
នោះត្រង់នោះសាគរ ឈ្មោះសីទន្តរ ប្រាកជ្រៅពេកក្រៃ ៗ
ទឹកស្អិតហៅផែតសរសៃ ធ្លាក់អ្វីដល់ព្ញ ទឹកសឹងលិចលង់ ៗ



ប្រាយប្រាប់ស្រេចស្រាប់ពអង្គ កាកីទៅត្រង់ សមុទ្រជលស័យ ៗ
ដល់ស្រេចទើបស្តេចវេនតេយ្យ បង្ហាញទៅព្ញ សមុទ្រគង្គា ៗ
ប្អូនពៅនេះហៅជលសា ឈ្មោះលោណមហា សមុទ្រទឹកប្រៃ ៗ
ធំផ្ទាយទូលាយពេកក្រៃ ប្អូនអើយរំពៃ មើលមានមច្ឆា ៗ
ធំ ៗ នោះមកកាន់គ្នា តូច ៗ ហ្វូងវា ក្រាស់ក្រៃកន្ទង ៗ
ឯធំប៉ុនភ្នំជាម្តង កៀងគូត្រសង់ ហែបហែលដេញគ្នា ៗ
ប្រែប្រឹងសម្ទឹងរេក លេចលើគង្គា មើលហាក់គ្រើយត្រាណ ៗ
សន្ធឹកដំទឹកប្រឹងប្រាណ ហែបហែលលលាន លលេលលា ៗ
ខ្លះសោតលោលោតទៅពាំ ចំណីទន្ទាំ ទន្ទេងទៅមក ៗ
ខ្លារខ្លួរខ្វាយខ្លួរលេក មច្ឆាតូចជ្រក ខ្ទបខ្ទាចប្រួញប្រាណ ៗ
ប្អូនមាសវររាសមើលមាន ទ្វីបប្អូនជាស្ថាន មនុស្សលោកនៅនិត្យ ៗ
ទ្វីបនោះមានកោះប្រកិត ពីរពាន់ផុះផិត ជាតិជាបរិវារ ៗ
ប្រាប់គ្រប់សាយសព្វប្រការ ស្រេចនាំនាងនាថ ទៅភ្នំហេមពាន្ត ៗ
ដល់ហើយគ្រុឌឆ្លើយប្រាប់ក្ពាន ហៃប្អូនកល្យាណ មាសមើលគិរី ៗ
ហេមពាន្តជាស្ថានទូរទី មើលរ៉ប្អូនស្រី ជាធំស្កឹមស្កៃ ៗ

ប្អូនពៅមើលទៅនាព្រៃ ជាផ្លូវល្អក្រៃ ឥតឯគណនា ។
មើលមានជាស្ពានគុហា ស្រះស្រង់គង្គា ឈ្មោះអនោតាត្ត(១) ។
ទឹកស្រះថ្លាជ្រះជ្រៅស្អាត ក្នុងនោះគ្មានជាតិ ត្រីបចកឈើស្មៅ(២) ។
ហូរចេកប្អូនបែកវិលនៅ បីជុំហួសទៅ ចាំងប្អូនទិសទី ។
វេនគេយព្រៃនៃនារី ចុះស្រង់ស្រះស្រី ក្រសាលសប្បាយ ។
និរទុក្ខជាសុខស្រួលកាយ កាកៈធោមធាយ ក្រេមក្សាន្តទ័យា ។
ស្រង់ស្រេចទើបស្តេចបក្សា បីបមកៃវកា- គីកាយកល្យាណ ។
ប្រាប់ឲ្យមើលដោយក្តីមាន ព្រៃព្រះហេមពាន្ត ច្រើនក្រៃគណនា ។
ដុះដិតប្រកិតកពង្គា រៀបរាយផ្លូវរ៉ា ផ្កាផ្កាយោនយាន ។
ក្រអៃបក្សិនក្លែបសព្វហាន ក្រអូបផលមាន- រសវៃងពិសា ។
មាសថ្ងៃរំពៃមើលពី អុញហ៊ុនសត្វាវ កៀងគូឈ្មោលញី ។
ដូចបង់ត្រកង់ប្អូនស្រី នៃបទូវឥន្ទ្រិយ ពុំឲ្យឃ្លាតឃ្លា ។
ប្អូនគន់គួរគន់ពញ្ញា ពញាក់វេក វេរកទំនៅ ។

១- តាមសព្ទដើមគឺ អនោតត្ត, តែដោយតម្រូវឲ្យចួននឹងសម្ផស្សពាក្យខាងចុងថា "ស្អាត" ទើបសរសេរជាអនោតាត្ត ។ ២ ច្បាប់ខ្លះថា ត្រីបកឈើស្មៅ ។



ប្អូនភ្ញាមើលពិចទៅ ចចាតហើរទៅ ហើរចាបហើយយំ ។
មាសស្នេហ៍មើលឯស្រគំ ស្រកា(១) ហើរទំ ហើរទៅខ្ទបខ្នាំង ។
ប្អូនអើយនោះហើយក្រសាំង ក្រសារសំកាំង សំកុលកន្ទុយ ។
ប្អូនមាសវរវាសមើលគុយ មើលគូកហើរព្រួយ ហើរព្រាតវៀងកយ ។
ប្អូនពៅមើលទៅប្រពាយ ពពេចប្រញាយ ប្រញាប់ទំផ្កាស ។
ប្អូនថ្ងៃរំពៃមើលពាស មើលពាវទំជ្រាស ជ្រៀវជ្រើមជ្រប់ជ្រក ។
ប្អូនគន់គួរគន់មើលធ្នូក មើលក្ដុំហើរមក ហើរមីរវិលវង់ ។
ទើស្រស់ស្រីមើលខ្ទង មើលខ្ទែងរេរង់ រោសទន្សឹម ។
ស្រីស្រស់មើលអស់ទទឹម ទទាទំផ្ទឹម ទំផ្លាប់គូរ៉ ។
ស្រីស្រស់មើលអស់ម្រឹគា ម្រឹគីនានា ច្រើនណាស់ក្រាស់ក្រៃ ។
សីហាក្ងៀវក្លានិរភ័យ និរកិតជាញជ័យ នៅនឹងសីហោ ។
សិង្ហសេះគជកែះគោគគោ លៀងកាខ្លាគោ កៀរកាល់ឈ្មោល-
ញី ។
នរសិង្ហនៅនឹងនរសីហ៍ មាសមើលចាមរី នៅនឹងចាមរា ។

១ ដែលត្រូវ ហៅថា សារិកា , តែប្រើក្នុងទីនេះ តម្រូវឲ្យរត់គ្នានឹងពាក្យខាងដើម ។

វេនតេយ្យពៃនជាយា　ទតសព្វបព្វតា　ដលស័យព្រៃស្ថាន ។
៦៩- ហើយហោះហាក់ព្យុះលុះបាន ដល់ទីពិមាន សិម្ពលីព្រឹក្សព្រៃ ។
គ្រុឌសុខនិទ្ទុក្ខពេកក្រៃ កាកីមួលមៃ-　ត្រីត្រេកចិន្តា ។

## បទព្រហ្មគីតិ

៤៧- បទព្រហ្មគីតិគន់　កាលសុបណ្ណពដបក្សា
នឹងកាកីជាយា　រួមភិរម្យសុខសម្រាន្ត ។
លុះគ្រប់សត្តទិវា　ក្រុងគ្រុឌាគន់គិតជ្យាន
ថាកាលអញលួចបាន　កែវកាកីមកស្នេហា ។
បានប្រាំពីរថ្ងៃគត់　ជួបកំណត់ទៅលេងស្កា
បើអញពុំយាត្រា　សមគេគន់គិតសង្ស័យ ។
៥០- គិតស្រេចលួងលោមថា　ហៃកែវកាកីថ្មើមថ្ងៃ
ឥឡូវជួបដួនថ្ងៃ　បងតែងតែទៅលេងស្កា ។
ចូរនាងនៅណាហៅ　បងលាទៅតែពេលា
រសៀលព្រះសុរិយា　នោះបងមកដល់មិនខាន ។
កាកីស្ដាប់គ្រុឌា　ទើបវន្ទាទៀងទូលឋាន



ជាបពិត្រព្រះមានៈ　គុណគួរគន់គិតប្រណី ។
កាកីនៅកន្ទង　តែឯកឯងអង្គជាស្រី
ធ្លាប់មានព្រះចក្រី　គ្រាន់ជាពីរនាក់និត្យនៅ ។
មិនគប្បីឃ្លាឃ្លាត　ពីព្រះបាទព្រះបងទៅ
ប្អូនអន់ប្អូនអួលក្តៅ　តែងប្រយ័ត្នប្រយោជន៍ប្រាណ ។
៥៤- ប្អូនខ្លាចអស់ខ្មោចព្រៃ　ស្នេះស្និតព្វទូរទីស្ថាន
ពាំងយក្សយង់សាមាន្យ　ពិទ្យាធរវង់បុទ្ធិវង្គ ។
មានឫទ្ធិមានជយា　ពាលពាលាពាលាពង្ស
ពុះពារពះពើបអង្គ　ខ្ញុំម្ចាស់អើយមករួមស្ថាន ។
ខ្លាចខ្លួនជាតិជាស្រី　គឫទ្ធីតើម្ដេចបាន
បើគេមករួមស្ថាន　សមកាកីរង់ជួក្រៃ ។
ប្រុសមួយហើយលែងបង់　មករួមអង្គប្រុសដទៃ
ពីរអង្គពុំប្រពៃ　ម្ដេចថែមប្រុសមួយទៀតផង ។
ជាប់ប្រាណប្រុបគត់　ខុសកំណត់ច្បាប់កន្ទង
ដូច្នេះសូមព្រះបង　ព្រះបាទកុំចរលីលា ។

៦០- នាងទូលនាងខ្ញុំយំ ក្រាបប្រណម្យប្រនៀលនា
ព្រះបាទព្រះបក្សា សោកឥតអាក់ឥតឯស្បើយ ៗ
គ្រុឌស្ដាប់អស់សំដី លោមទៅឲ្យល្ហៃល្ហើយ
ទុក្ខទៀងទើបផ្ចាស់ឆ្លើយ កាន់កែវកាកីថ្លើមថ្លៃ ៗ
ប្អូនអើយបើបងពុំ លីលាសមគេគិតថ្លៃ
ជាបងល្អួចប្អូនថ្លៃ គ្រកាលកាយមកស្នេហ៍ស្នង ៗ
បងទៅមាសកុំគិត កុំព្រួយចិត្តណា៎មាសបង
បងបេះអាគមចង ទ្វារប្រាសាទជាប់ក្ដាំងក្ដាត់ ៗ
ទោះតាំងទេពទេវ៉ា យក្សពិទ្យាធរសិល្បសិទ្ធិ
អាក្រក់ខ្មោចរីងថ្មចិត្ត ពុំទម្លុះទម្លាយបាន ៗ
៦៥- នាងនៅណា៎នាងណា៎ កុំសោកាឡើយកល្យាណ
កុំទល់កុំទុក្ខប្រាណ កុំអាឡោះអាល័យឡើយ ៗ
បងទៅ ៗ ពុំយូរ តែព្រះសុរិយាល្ងាចហើយ
បងវិលមកមាសអើយ ចូរនាងនៅណា៎នាងណា៎ ៗ
ប្រាប់ហើយគ្រុឌគ្រកង លោមស្នេហ៍ស្នងស្រេចយាត្រា



ដល់ក្រៅទ្វារប្រាង្គណ៍ប្រា- សាទសេកបង់ទ្វារជាប់ក្ដាត់ ៗ
ហើយប្រែប្រាណវិញជា គ្រុឌបក្សាសហ័សឫទ្ធិ
ស្ទុះចេញពីស្ថានសិត ហៀរហោះហាហួសដួចដល់ ៗ
ដើមជ្រៃហើយចូលចាប់ ប្រែក្រឡាប់កាយឲ្យយល់
ជាមាណពដូចកល ដូចកាលមុននៅនាជ្រៃ ៗ
៧០- ក្រុងគ្រុឌប្រែកាឡា ស្រេចយាត្រាឆ្ពោះទៅឰ
ប្រាសាទមហាក្សត្រថ្លៃ ដល់ស្រេចហើយចរចូលឋាន ៗ
ឯអង្គមហាក្សត្រា យល់គ្រុឌាទើបស្ដេចមាន
ព្រះស្ងួនមន្ទុលឋាន នឹងក្រុងគ្រុឌសោះសង្ស័យ ៗ
តែក្នុងព្រះទយា ក្រេវក្រោធាពន់ពេកក្រៃ
គ្រុឌសោកសឹងសង្ស័យ នឹករអៀសអង្គអាត្មា ៗ
ព្រះបាទព្រះព្រហ្មទត្ត ស្ដេចទ្រង់អត់ព្រះក្រោធា
ហើយត្រាស់ឲ្យយកស្កា មកក្រសាលដូចសព្វដង ៗ
លង់លុះព្រះសុរិយេ ទន់ទាបជ្រេគ្រុឌច្រើសយួង
ទឹកកាកីកន្ទង ហើយលុតលាព្រះទោមទៅ ៗ